# ការរក្សាការសម្ងាត់ក្នុងសំណុំរឿងពេទ្យរបស់លោកអ្នក
**Protect Your Medical Privacy**
**A Federal law, called HIPAA, is designed to safeguard patient right**

ក្នុងឋានៈជាអ្នកជម្ងឺ លោកអ្នកប្រហែលជាត្រូវសរសេរឈ្មោះនៅលើលិខិតពេទ្យផ្សេងៗ ជាច្រើនក្នុងមួយឆ្នាំៗ។ លិខិតមួយដែលមាននៅក្នុងនោះ គឺ ការចុះហត្ថលេខាទទួលស្គាល់ ថា លោកអ្នកបានទទួលយកលិខិតមួយស្តីអំពីការរក្សាការសម្ងាត់របស់អ្នកជម្ងឺនៃមណ្ឌលសុខភាព ឬមន្ទីពេទ្យនីមួយៗ។ ឯលិខិតនោះហៅថា លិខិតបញ្ជាក់អំពីការរក្សាការសម្ងាត់របស់អ្នកជម្ងឺ ឬ "Notice of Privacy Practices"។

ជាទូទៅលិខិតនេះបញ្ជាក់អំពីសិទ្ធិរបស់លោកអ្នក ក្នុងឋានៈជាអ្នកជម្ងឺ យោលទៅតាមច្បាប់ សហពន្ធដែលហៅថា Health Insurance Portability and Accountability Act (HIPAA)។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណង ដើម្បីការពារសំណុំរឿងពេទ្យនៅក្នុងសហរដ្ឋ។

មុនពេលមានច្បាប់នេះ គេត្រូវពឹងផ្អែកទាំងស្រុងទៅលើច្បាប់រដ្ឋផ្សេងៗ ដែលសំរាប់ការពារ សំណុំរឿងពេទ្យ ជួនកាលច្បាប់ទាំងនោះមានប្រសិទ្ធភាពខ្លះ ហើយពេលខ្លះទៀតវា ពុំមាន ប្រសិទ្ធភាពឡើយ។ ប៉ុន្តែតាំងចាប់ពីថ្ងៃទី 14 ខែ មេសា ឆ្នាំ 2003 មក មន្ទីរពេទ្យ, មណ្ឌល សុខភាព, ក្រុមហ៊ុនធានារ៉ាប់រងសុខភាព, និង Pharmacy ត្រូវតែអនុវត្តទៅតាមច្បាប់តែមួយ ដូចគ្នាទូទាំងសហរដ្ឋ។ ជាមួយគ្នានេះ ច្បាប់រដ្ឋក៏នៅតែមានប្រសិទ្ធភាពដដែល។

ច្បាប់ HIPAA បានត្រូវបង្កើតឡើងសំរាប់ការពារអ្នកជម្ងឺ ដោយរួមទាំងសិទ្ធិក្នុងការទទួលយក សេចក្តីចម្លងសំណុំរឿងពេទ្យរបស់ខ្លួនផងដែរ។ ជាមួយគ្នានេះ អ្នកជម្ងឺអាចសុំឲ្យកែនូវសេចក្តី ណាមួយនៅក្នុងសំណុំរឿងពេទ្យ ដែលពុំត្រឹមត្រូវ។ នៅពេលសុំសេចក្តីចម្លងសំណុំរឿងពេទ្យ អ្នកជម្ងឺប្រហែលជាត្រូវចេញ ថ្លៃក្រដាសនិងតែម្រ ដែលមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ត្រូវផ្ញើ ទៅឲ្យកន្លែង ដែលតាមសេចក្តីស្នើសុំ។

នៅពេលដែលច្បាប់នេះការពារកុំឲ្យមន្ទីរពេទ្យឬមណ្ឌលសុខភាពបញ្ជូនពត៌មានផ្សេងៗ ដោយ ពុំមានការអនុញ្ញាតិពីអ្នកជម្ងឺ ច្បាប់នេះក៏បានផ្តល់សិទ្ធដល់ មន្ទីរពេទ្យនិងមណ្ឌលសុខភាពទាំង នោះ ឲ្យបញ្ជូនពត៌មានផ្សេងៗ ទៅក្រសួងដទៃទៀត ក្នុងគោលបំណងដើម្បី ព្យាបាលជម្ងឺ, បង់ថ្លៃមើលជម្ងឺ, និងការចាត់ចែងសុខភាពទូទៅបានដែរ។ ឧទាហរណ៍ ដូចជា មន្ទីពេទ្យឬ មណ្ឌលសុខភាពអាចមានសិទ្ធផ្តល់ពត៌មានអំពីរោគគ្រុនផ្តាសាយធំទៅក្រសួង សាធារណៈ សុខាភិបាល ឬរាយការណ៍អំពីគ្រោះថ្នាក់ដែលទាក់ទងនឹងគ្រឿងអាវុធទៅ ក្រសួងប៉ូលិស

ហើយជាមួយគ្នានេះ អ្នកជម្ងឺក៏អាចមានសិទ្ធនឹងសុំបញ្ជីឈ្មោះ ឬក្រសួងទាំង ប៉ុន្មានដែល មន្ទីពេទ្យឬមណ្ឌលសុខភាពនោះផ្ញើពត៌មានរបស់ខ្លួនទៅ ក្នុងមួយឆ្នាំកន្លងនិងអំពីមូលហេតុ ដែលផ្ញើនោះបានដែរ។

ច្បាប់ HIPAA បានហាមប្រាម កុំឲ្យមន្ទីពេទ្យឬមណ្ឌលសុខភាពបញ្ជូនសំណុំរឿងពេទ្យ របស់អ្នកជម្ងឺទៅកន្លែងក្រសួង ដែលពុំមានទាក់ទងទៅនឹងការព្យាបាលជម្ងឺ ហើយដែល ពុំមានការអនុញ្ញាតិពីអ្នកជម្ងឺ ដូចជាក្រុមហ៊ុនពាណិជកម្ម ឬក្រុមហ៊ុនផ្សាយលក់ថ្នាំណាមួយ។

នៅក្នុងករណីដែលមន្ទីពេទ្យ ឬមណ្ឌលសុខភាពបំពាន់លើច្បាប់នេះ អ្នកជម្ងឺអាចមានសិទ្ធ នឹងប្តឹងទៅមន្ទីពេទ្យឬក្រុមហ៊ុនធានារ៉ាប់រងសុខភាពរបស់ខ្លួនបាន។

រួមសេចក្តីមក ការចុះហត្ថលេខាក្នុងលិខិតនោះ គ្រាន់តែបានន័យថា លោកអ្នកទទួលស្គាល់ថា បានទទួលលិខិតចម្លងរបស់ច្បាប់ថ្មី ដើម្បីរក្សាសិទ្ធិរបស់អ្នកជម្ងឺតែប៉ុណ្ណោះ គឺពុំមែនបានន័យ ថា លោកអ្នកចុះហត្ថលេខាយល់ព្រមឲ្យមន្ទីពេទ្យ ឬមណ្ឌលសុខភាពបញ្ជូនសំណុំរឿង ទៅ មន្ទីរពេទ្យផ្សេងឬមណ្ឌលសុខភាពផ្សេងនៅឡើយ។

សូមបញ្ជាក់ថា ការសុំឲ្យចុះហត្ថលេខានេះ គឺមាននៅតុមុខ មុនពេលជួបជាមួយគ្រូពេទ្យ។ បន្ទាប់ពី គ្រូពេទ្យពិនិត្យហើយ គ្រូពេទ្យប្រហែលជាត្រូវសុំការអនុញ្ញាតិពីលោកអ្នក ដើម្បីសុំ សំណុំរឿង ពេទ្យពីគ្រូពេទ្យដទៃទៀតដែលលោកអ្នកធ្លាប់អញ្ជើញទៅពីនិត្យព្យាបាលរោគ។

ចំពោះពត៌មានស្តីអំពីច្បាប់សហពន្ធ ការពារសំណុំរឿងពេទ្យ ដែលហៅថា Health Insurance Portability and Accountability Act ឬ (HIPAA) នេះ  សូមអានវិបសៃរបស់ក្រសួង សុខភាពនិងមនុស្សធម៌នៃសហរដ្ឋអាមេរិក (Department of Health and Human Services ដែលមានអាសយដ្ឋាន  www.hhs.gov។ ឬសាកសួរគ្រូពេទ្យប្រចាំកាយរបស់លោកអ្នកផ្ទាល់។

អត្ថបទនេះ ដកស្រង់និងបកប្រែចេញពី Healthfinder ដែលជាកម្មវិធីនៃក្រសួងសុខភាព និងមនុស្សធម៌នៃសហរដ្ឋអាមេរិក (Department of Health and Human Services) ដោយ មណ្ឌលមេត្តាសុខភាព នៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។

http://www.healthfinder.gov/news/newstory.asp?docID=532562